**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន ស្តីពី
# ទិវាប្រាក់រៀល អបអរសាទរខួបលើកទី៣៧ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ

២០ មីនា ១៩៨០ - ២០ មីនា ២០១៧

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបអំពីការរៀបចំ "ទិវាប្រាក់រៀល" ខួបលើកទី៣៧ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ដែលប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ទិវានេះបានចូលរួមពីសំណាក់តំណាងមកពី ក្រសួង ស្ថាប័ន រាជរដ្ឋាភិបាល អង្គការអន្តរជាតិ សភាពាណិជ្ជកម្មនានា ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងសិស្ស និស្សិត ប្រមាណជាង៣០០នាក់។ ការចូលរួមពីភាគីពាក់ព័ន្ធទាំងនេះ ជាពិសេស ពីសំណាក់សភាពាណិជ្ជកម្មកម្ពុជា និងសមាគមសហគ្រិនវ័យក្មេងកម្ពុជា បានបង្ហាញពីការគាំទ្រពីគ្រប់វិស័យ និងការយល់ដឹងអំពីសារៈសំខាន់នៃតួនាទីប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចនិងសង្គម។

ពិធីនេះបានប្រព្រឹត្តទៅក្រោមបរិយាកាសអធិកអធម សប្បាយរីករាយ សាមគ្គីភាព និងមោទនភាពបំផុត។ តាមរយៈបទបង្ហាញរបស់វាគ្មិនដែលជាតំណាងមកពីមជ្ឈដ្ឋានពាណិជ្ជកម្ម និងវិស័យហិរញ្ញវត្ថុ ឃើញថា ប្រាក់រៀលត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ហើយនិន្នាការនេះរំពឹងថានឹងបន្តកើនឡើងបន្ថែមទៀតនាពេលអនាគត។ អង្គពិធីទាំងមូលបានសម្តែងការសាទរនិងស្មារតីប្តេជ្ញាចិត្តខ្ពស់ក្នុងការបន្តបេសកកម្មលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលប្រកបដោយសុទិដ្ឋិនិយមនិងមោទនភាពជាតិនេះបន្តទៀត ដើម្បីពង្រឹងអត្តសញ្ញាណជាតិ អធិបតេយ្យភាពរូបិយវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងសង្គម។

ធនាគារជាតិនៃកម្ពុជា សូមសម្តែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការចូលរួមដ៏ច្រើនកុះករនាព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ នេះ ជាពិសេស សូមថ្លែងអំណរគុណដល់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច កាសែតខ្មែរថាមស៍ ក្រុមហ៊ុនសែលកាត ធនាគារឯកទេសវីងនិងក្រុមហ៊ុន Tous Les Jours ដែលបានសហការនិងឧបត្ថម្ភក្នុងការរៀបចំទិវាប្រាក់រៀលនាថ្ងៃនេះឱ្យប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

ប្រាក់រៀលជារបស់យើងទាំងអស់គ្នា ដូច្នេះយើងទាំងអស់គ្នាមានកាតព្វកិច្ចការពារ និងប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយ ដើម្បីលើកស្ទួយសេដ្ឋកិច្ចនិងសង្គមជាតិយើងទាំងអស់គ្នា។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧